គណៈកម្មការរៀបចំខួបទី៣០
ទិវាជ័យជំនះ ៧ មករា ឆ្នាំ២០០៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំ
បុណ្យជាតិ-អន្តរជាតិ

# សូមជម្រាបជូន
# ឯកឧត្តម រដ្ឋមន្ត្រីក្រសួងពត៌មាន

<u>សូមជ្រាប</u>

*ឯកឧត្តម រដ្ឋមន្ត្រី ជាទីរាប់អាន,*

ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៣០ នៃទិវាជ័យជំនះ ៧ មករា កាលពីថ្ងៃពុធ ទី៧ ខែមករា ឆ្នាំ២០០៩ កន្លងមកនេះ បានប្រព្រឹត្តទៅប្រកបដោយលទ្ធផល និងជោគជ័យយ៉ាងល្អប្រសើរ ឆ្លើយតបយ៉ាងសក្តិសមទៅនឹងគោលបំណង និងសំណូមពររបស់គណបក្សប្រជាជនកម្ពុជា និងរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

ជាពិសេស ការយកចិត្តទុកដាក់កម្រិតខ្ពស់របស់ **ឯកឧត្តម រដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកក្នុងឱវាទ មានវិទ្យុ ទូរទស្សន៍ អ្នកយកពត៌មាន អ្នកថតរូបជាដើម ដែលបានរួមសហការល្អ ក្នុងការត្រៀមលក្ខណៈបំរើសេវាផ្សព្វផ្សាយ តាំងពីការហ្វឹកហាត់សាកល្បង រហូតដល់ថ្ងៃប្រារព្ធពិធី និងចូលរួមគ្រប់សកម្មភាព បំរើការរៀបចំមហាមីទិញ និងការរៀបចំព្យុហយាត្រាមហាជន ប្រកបដោយទស្សនីយភាពដ៏ល្អស្រស់ត្រកាល ភ្ជាប់ទៅនឹងខ្លឹមសារអត្ថន័យ និងការអភិវឌ្ឍន៍ប្រែប្រួលថ្មីគ្រប់វិស័យ ពិតជាបានធ្វើឱ្យមតិជាតិ និងអន្តរជាតិ ជក់ចិត្តចាប់អារម្មណ៍ និងពោលកោតសរសើរ គ្រប់ៗគ្នា។

សកម្មភាពប្រកបដោយមនសិការជាតិ និងគំនិតច្នៃប្រឌិតប្រកបដោយទេពកោសល្យគួរកោតសរសើរនេះ មិនត្រឹមតែបង្ហាញអំពីតួនាទីភារកិច្ច និងសមិទ្ធផលដែលកើតឡើងពីការខិតខំរបស់សមាជិក សមាជិកាគណបក្សប្រជាជនប៉ុណ្ណោះទេ, ប៉ុន្តែ គឺជាការឆ្លុះបញ្ចាំងអំពីការអនុវត្តន៍ដោយជោគជ័យ នូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការការពារអត្តសញ្ញាណជាតិ និងការប្រែប្រួលរីកចំរើនថ្មីនៃសង្គមជាតិផងដែរ។

គណៈកម្មការកណ្តាលរៀបចំបុណ្យខួបទី៣០ ទិវាជ័យជំនះ ៧មករា និងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមគោរពកោតសរសើរ និងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម រដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ដែលបានរួមសហការខិតខំរៀបចំបុណ្យខួបទី៣០ ទិវាជ័យជំនះ ៧មករា ប្រកបដោយជោគជ័យលើសពីការស្មាន និងសូមជូនពរបវរសួស្តី សុភមង្គល វិបុលសុខគ្រប់ប្រការ ជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ឯកឧត្តម រដ្ឋមន្ត្រី** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

ភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៩

**ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**
**អនុប្រធានទី១ គណៈកម្មការកណ្តាលរៀបចំបុណ្យ**
**ខួបទី៣០ ទិវាជ័យជំនះ ៧ មករា**

**សម្តេចចៅហ្វាវាំង វាំងវរវៀងជ័យ អធិបតីស្រីឋារ គង់ សំអុល**